- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញសំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១.- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោកស្រី ឡុក សៀវម៉ាន់ សេម៉ុន ( LUK SIU MAN SEMON ) សញ្ជាតិចិន កើតថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៥៦ នៅក្រុងហុងកុង នៃ សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះមានអានុភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧០ អនក្រ.បក

### ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមទីប្រឹក្សាឧបសម្ព័ន្ធ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងដែលបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០០ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទប្បញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យ ហិរញ្ញវត្ថុលើការចំណាយរបស់ទីភ្នាក់ងារតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង សម្ភារសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១._**

អនុក្រឹត្យនេះ កំណត់នូវវិធានទាំងឡាយ សំរាប់អនុវត្តថវិកាឧបសម្ព័ន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ជំពូកទី ២**

**ថវិកាឧបសម្ព័ន្ធ**

**មាត្រា ២._**

ថវិកាឧបសម្ព័ន្ធ គឺជាកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាពរដ្ឋ ដែលមានលក្ខណៈឧស្សាហកម្ម និង ពាណិជ្ជកម្មតែមិនមែនជានីតិបុគ្គលទេ ។

ថវិកាឧបសម្ព័ន្ធ ត្រូវបានបង្កើតឡើង ឬលុបចោលដោយច្បាប់ហិរញ្ញវត្ថុ ។

www.pheakdeylaw.com

អង្គភាពណាក៏ ដែលអនុវត្តថវិកាឧបសម្ព័ន្ធ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរួមរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នសាមី ។

មាត្រា ៣ .-

អង្គភាពណាក៏ដែលមានលក្ខណៈឧស្សាហកម្ម និង ពាណិជ្ជកម្ម គឺជាអង្គភាពណាដែលផលិតវត្ថុធាតុ ឬ ផ្ដល់សេវា ដែលត្រូវការការបង់ថ្លៃពីអ្នកទទួលផល ។

មាត្រា ៤ .-

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ នៃ ថវិកាឧបសម្ព័ន្ធ ត្រូវអនុវត្តទៅតាមវិធាន និងតាមវិធានដូចគ្នានៃ កិច្ចប្រតិបត្តិការរបស់ថវិកាជាតិ ។ កិច្ចប្រតិបត្តិការទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយមាន ជាអាទិ៍ ៖

-ច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១.នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ១៩៩៩

-អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃ គណនេយ្យ សាធារណៈ ( ពិសេសមាត្រា ៣ មាត្រា ៥ មាត្រា ១២ មាត្រា ៤៥ ដល់មាត្រា ៥៦ និងមាត្រា ៩៨ ដល់មាត្រា ១០០ ) ។

-អនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិកា នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គភាពសាធារណៈនានា ( ពិសេសពីមាត្រា ១ ដល់មាត្រា ៨ ) ។

-អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្ដីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ( ពិសេស មាត្រា ១ ដល់មាត្រា ៨ ) ។

## ជំពូកទី ៣

## ភារកិច្ចរបស់អាណាប័កដើមខ្សែ និង ភ្នាក់ងារគណនេយ្យកណ្ដាល

មាត្រា ៥ .-

រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នគឺជាអាណាប័កដើមខ្សែនៃចំណូល និង ចំណាយ នៃថវិកាឧបសម្ព័ន្ធ ។ អាណាប័កដើមខ្សែអាចប្រគល់សិទ្ធិជូនប្រធានអង្គភាព ដែលមានថវិកាឧបសម្ព័ន្ធ ។

អាណាប័កដើមខ្សែ អាចអោយអាណាប័កផ្ទេរសិទ្ធិ ទទួលខុសត្រូវក្នុងការសន្យាចំណាយ និងការធ្វើអាណត្តិបើកប្រាក់ចំណាយមួយចំនួននៃថវិកាឧបសម្ព័ន្ធ ក្រោយពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

www.pheakdeylaw.com

មាត្រា ៦ .

កិច្ចប្រតិបត្តិការចំណូល និងចំណាយនៃថវិកាឧបសម្ព័ន្ធ ត្រូវបានប្រតិបត្តិការដោយភ្នាក់ងារគណនេយ្យករសាធារណៈម្នាក់ដែលបានតែងតាំងដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ឬស្ថាប័នសាមី ។ ភ្នាក់ងារគណនេយ្យករសាធារណៈ ទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ទៅតាមបទប្បញ្ញត្តិនានា នៃបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

តាមការស្នើរបស់ភ្នាក់ងារគណនេយ្យករសាធារណៈ អាចប្រគល់សិទ្ធិដល់ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធ នៅតាមខេត្ត ក្រុង ដោយប្រកាសរបស់រដ្ឋមន្ត្រីនៃក្រសួង ឬស្ថាប័នសាមីរួមគ្នា ។ ការតែងតាំងភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធទាំងនេះ ត្រូវបានតែងតាំងតាមលក្ខខណ្ឌដូចគ្នា នឹងការតែងតាំងភ្នាក់ងារគណនេយ្យករសាធារណៈ ។

មាត្រា ៧ .

ភ្នាក់ងារគណនេយ្យករសាធារណៈ មានលក្ខណសម្បត្តិជាគណនេយ្យករជាន់ខ្ពស់ ។ ភ្នាក់ងារគណនេយ្យករសាធារណៈត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យហិរញ្ញវត្ថុ ។

មាត្រា ៨ .

ភ្នាក់ងារគណនេយ្យករសាធារណៈ ត្រូវទទួលខុសត្រូវលើការប្រមូលចំណូល និង ការទូទាត់ចំណាយថវិកាឧបសម្ព័ន្ធ ។ មុននឹងធ្វើការទូទាត់ ភ្នាក់ងារគណនេយ្យករសាធារណៈ ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ទាំងអស់នៃថវិកាឧបសម្ព័ន្ធរបស់ខ្លួន ។

ភ្នាក់ងារគណនេយ្យករសាធារណៈ មានសិទ្ធិបដិសេធចំពោះការទូទាត់ចំណាយទាំងឡាយណា ដែលមានលក្ខណៈមិនត្រឹមត្រូវ ។

មាត្រា ៩ .

ភ្នាក់ងារគណនេយ្យករសាធារណៈ ត្រូវប្រមូលផ្តុំនៅក្នុងគណនីរបស់ខ្លួន នូវរាល់កិច្ចប្រតិបត្តិការដែលភ្នាក់ងារគណនេយ្យ នៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង បានអនុវត្ត ។

## ជំពូកទី ៤

## ភារកិច្ចរបស់អាណាប័កផ្ទេរសិទ្ធិ និងភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង

មាត្រា ១០ .

ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធ នៅតាមខេត្ត-ក្រុង ត្រូវអនុវត្តកិច្ចប្រតិបត្តិការរបស់អាណាប័កផ្ទេរសិទ្ធិនៃថវិកាឧបសម្ព័ន្ធនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ។ ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធ ត្រូវទទួលបន្ទុកនូវរាល់កិច្ចប្រតិបត្តិការចំណូល និង ចំណាយ ដែលបានកំណត់ដោយបទបញ្ជាដោយឡែករបស់អង្គភាពសាមី ។

ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង គឺជាគណនេយ្យករបើកផ្តល់ចំណាយនៃអាណត្តិបើកប្រាក់ ដែលបានធ្វើឡើងដោយអាណាប័កផ្ទេរសិទ្ធិ នៃថវិកាឧបសម្ព័ន្ធ និង ទទួលបន្ទុកបើកផ្តល់ចំណាយក្នុងដែនដីរបស់ខ្លួន ។

www.pheakdeylaw.com

ភ្នាក់ងារគណនេយ្យ នៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង មានសិទ្ធិជំទាស់ទៅនឹងការទូទាត់ចំណាយ ដែលមិនត្រឹមត្រូវ ។

មាត្រា ១១ ._

ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង មានលក្ខណសម្បត្តិជាគណនេយ្យកររង ។

មាត្រា ១២ ._

ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង ត្រូវផ្តល់នូវរបាយការណ៍គណនេយ្យប្រចាំខែ ដោយមានភ្ជាប់មកជាមួយនូវលិខិតយុត្តិការណ៍ការចំណូល ចំណាយ ជូនភ្នាក់ងារគណនេយ្យកណ្តាល ដើម្បីធ្វើការបូកសរុបផ្ទៀងផ្ទាត់នូវកិច្ចប្រតិបត្តិការទាំងនោះ ជាមួយគណនេយ្យរបស់ខ្លួនលើការរៀបចំ គណនីទូទៅក្នុងពេលបិទបញ្ជី ។

គណនីគ្រប់គ្រងទាំងនោះ ត្រូវបានបញ្ជាក់ទទួលស្គាល់ដោយរដ្ឋមន្ត្រីទទួលបន្ទុកអនុវត្តថវិកាឧបសម្ព័ន្ធ អំពីភាពត្រឹមត្រូវនៃលេខនារបស់គណនេយ្យករ ។

## ជំពូកទី ៥

## គណនេយ្យទូទៅ និង គណនេយ្យវិភាគ

មាត្រា ១៣ ._

គណនេយ្យទូទៅនៃថវិកាឧបសម្ព័ន្ធ ត្រូវបានកាន់កាប់ជាគណនេយ្យទ្វេភាគទៅតាមប្លង់មួយ ដូចគ្នានឹងប្លង់គណនេយ្យទូទៅដែរ ។

គណនេយ្យទូទៅនេះ ត្រូវអនុញ្ញាតអោយកំណត់ថ្លៃដើមអាជីវកម្ម និង លទ្ធផលហិរញ្ញវត្ថុ ដែលជាមូលដ្ឋានសំរាប់វាយតំលៃការគ្រប់គ្រងហិរញ្ញវត្ថុ និង ពិនិត្យប្រមាណស្ថានភាពទ្រព្យសកម្ម និង ទ្រព្យអកម្មរបស់អង្គភាព ។

មាត្រា ១៤ ._

ក្រៅពីគណនេយ្យទូទៅ ភ្នាក់ងារគណនេយ្យកណ្តាល ត្រូវកាន់កាប់គណនេយ្យវិភាគ ដែលបង្ហាញពីការគិតគូរថ្លៃដើម ។

គោលជំហរ និង បែបបទនៃការរៀបចំគណនេយ្យវិភាគនេះ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរួមជាមួយនឹងរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នសាមី ។

មាត្រា ១៥ ._

ភ្នាក់ងារគណនេយ្យកណ្តាល និង ភ្នាក់ងារគណនេយ្យនៃថវិកាឧបសម្ព័ន្ធនៅតាមខេត្ត ក្រុង ត្រូវកាន់កាប់រៀងៗខ្លួននូវគណនេយ្យរូបធាតុនៃចលនវត្ថុ អចលនវត្ថុ និងតំលៃ ជាកម្មសិទ្ធិរបស់អង្គភាពដែលអនុវត្ត ថវិកាឧបសម្ព័ន្ធ ។

www.pheakdeylaw.com

**មាត្រា ១៦ ._**

នាចុងការិយបរិច្ឆេទ ភ្នាក់ងារគណនេយ្យកណ្តាល ជាប្រធានគណនេយ្យទូទៅនៃថវិកាឧបសម្ព័ន្ធ ត្រូវរៀបចំនូវគណនីលទ្ធផល និង តុល្យការ ។

**មាត្រា ១៧ ._**

គណនីប្រចាំខែ និងគណនីបញ្ចប់នៃការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យកណ្តាល ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមកាលបរិច្ឆេទដែលកំណត់ដោយគណនេយ្យករនៃថវិកាទូទៅរបស់រដ្ឋ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ ។

គណនីប្រចាំឆ្នាំនៃការគ្រប់គ្រង ត្រូវចុះទិដ្ឋាការជាមុនដោយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នដែលរអាណាព្យាបាលលើភាពត្រឹមត្រូវទៅនឹងលេខនាំរបស់គណនេយ្យករកណ្តាលសាមី ។

**មាត្រា ១៨ ._**

ប្រាក់ទំនេរក្នុងបេឡាដែលបានមកពីអាជីវកម្ម នៃអង្គភាពដែលមានថវិកាឧបសម្ព័ន្ធត្រូវបញ្ចូលក្នុងគណនីប្រាក់បញ្ញើនៅរតនាគារ ដែលបានបើកក្នុងនាមអង្គភាពរបស់ខ្លួន ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២០ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមគ្រប់ក្រសួង រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត់ ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

www.pheakdeylaw.com